# ករណីសិក្សាស្ដីពីឧបករណ៍មិនបង្កទំនាស់

## គម្រោងសហគមន៍នេសាទ អេ អែហ្វ អែស ស៊ី និង ជម្លោះនេសាទក្នុងឆកសមុទ្រកំពង់សោម

## ទិដ្ឋភាពទូទៅ

នៅដើមទសវត្សរ៍ឆ្នាំ ២០០០ គណៈកម្មាធិការសេវាកម្មមិត្តភាពអាមេរិក (AFSC) បានចាប់ផ្ដើមគម្រោងសហគមន៍នេសាទក្នុងស្រុកស្រែអំបិល ខេត្តកោះកុង នៅភាគខាងជើងនៃឆកសមុទ្រកំពង់សោម។ សហគមន៍នេសាទចំនួន២ ត្រូវបានបង្កើតឡើងក្នុងស្រុកស្រែអំបិល (*មួយនៅក្នុង ឃុំជីខក្រោម និង មួយទៀតនៅក្នុង ឃុំជ្រោយស្វាយ*)។ ក្នុងឆ្នាំ ២០០៤ អំពើហិង្សារវាងសហគមន៍នេសាទបានកើតឡើង ផ្ទះរបស់ពួកគេត្រូវបានលួចប្លន់ និងដុតបំផ្លាញ ហើយការិយាល័យកណ្ដាលរបស់សហគមន៍នេសាទ ដែលគាំទ្រដោយ (AFSC) ត្រូវបានដុតបំផ្លាញខ្ទេចខ្ទីអស់។

## សាវតា




- ប្រជានេសាទនៅស្រុកស្រែអំបិល កំពុងប្រើប្រាស់ឧបករណ៍នេសាទតាមបែបប្រពៃណី ចាប់តាំងពីការដួលរលំរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩។ ប្រជាពលរដ្ឋមួយចំនួនទៀត បានធ្វើស្រែចម្ការ ចិញ្ចឹមសត្វ កាប់ឈើខុសច្បាប់ និងជួញដូរសត្វព្រៃខុសច្បាប់។
- ឆ្នាំ ១៩៨៧ ច្បាប់ជលផល ត្រូវបានបង្កើតឡើង ដែលធ្វើឲ្យការនេសាទរបស់ពួកគេនៅក្នុងតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោមក្លាយជាការនេសាទខុសច្បាប់។ ប៉ុន្តែពួកគេមិនមានជម្រើសអ្វីផ្សេងទៀត សម្រាប់ការចិញ្ចឹមជីវិតឡើយ។
- ច្បាប់ជលផល ឆ្នាំ ១៩៨៧ មិនបានរាប់បញ្ចូលសហគមន៍នេសាទទេ
- ទោះបីជាយ៉ាងណា រដ្ឋាភិបាលបានផ្ដល់ការគាំទ្រដល់សហគមន៍នេសាទ ហើយនៅដើមទសវត្សរ៍ ២០០០ ច្បាប់ស្ដីពីសហគមន៍នេសាទត្រូវបានព្រាង[1]
- ក្រោយឆ្នាំ ១៩៩៩ អ្នកចំណូលថ្មីជាច្រើនដែលមកពីស្ទឹងហាវ បានមកដល់ស្រែអំបិល ដើម្បីធ្វើការនេសាទខុសច្បាប់
- ប៉ុន្តែក្នុងទសវត្សរ៍ឆ្នាំ ២០០០ នាយកដ្ឋានជលផល បានចាប់ផ្ដើមពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញានៅក្នុងវិស័យជលផល ដោយបានធ្វើការរួមជាមួយអាជ្ញាធរខេត្ត និងស្រុក។

[1] អនុក្រិតស្ដីពីសហគមន៍នេសាទត្រូវបានអនុម័តនៅ ខែ មិថុនា ឆ្នាំ ២០០៥ ហើយច្បាប់ជលផលថ្មីត្រូវបានប្រកាស់ឲ្យប្រើនៅ ខែ ឧសភា ឆ្នាំ ២០០៦

# ទំនាស់សហគមន៍នេសាទ

ទំនាស់ជលផលបានចាប់ផ្តើមនៅឆ្នាំ ១៩៨៩។ អ្នកនេសាទបានវាយសំណាញ់របស់ពួកគេនៅតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោម ដោយរំលោភលើច្បាប់ជលផល ឆ្នាំ ១៩៨៧។ កប៉ាល់នេសាទភាគច្រើន មកពីស្ទឹងហាវក្នុងខេត្តព្រះសីហនុ និងមានកម្មករនេសាទកម្ពុជាផងដែរ និង មានកប៉ាល់នេសាទផ្សេងទៀត មកពីប្រទេសថៃ និងវៀតណាម។ នៅពេលដែលកប៉ាល់នេសាទបានចូលមកដល់ អ្នកនេសាទក្នុងមូលដ្ឋានក្នុងស្រុកស្រែអំបិលបានវាយបកវិញ ហើយជារឿយៗបានលួចត្រីពីសំណាញ់/អួនកប៉ាល់នេសាទ។ ក្រុមកម្មករកប៉ាល់នេសាទ បានវាយបកទៅវិញ។ នៅចន្លោះឆ្នាំ ១៩៨៩ និង ២០០២ ក្រុមកម្មករកប៉ាល់នេសាទ បានសម្លាប់អ្នកនេសាទចំនួន ២២ នាក់នៅតំបន់នោះ។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ ២០០០ ដោយមានការពង្រឹងការអនុវត្តច្បាប់ និងការគ្រប់គ្រងរបស់រដ្ឋាភិបាល ទំនាស់ជលផលក្នុងតំបន់នោះបានថយចុះ។

យ៉ាងណាក៏ដោយនៅឆ្នាំ ២០០៤ អំពើហឹង្សាថ្មីរវាងក្រុមអ្នកនេសាទបានផ្ទុះឡើង។ ក្រុមកម្មករកប៉ាល់នេសាទមកពីស្ទឹងហាវ បានលួចប្លន់ និង ដុតបំផ្លាញផ្ទះសម្បែងប្រជានេសាទ និង ការិយាល័យកណ្តាលសហគមន៍នេសាទឃុំជីខក្រោម ដែលគាំទ្រដោយ AFSC ត្រូវបានដុតបំផ្លាញរាបដល់ដី។

**ទិដ្ឋភាពទូទៅនៃទំនាស់រួមមាន៖**

- ជាទូទៅអជ្ញាធរបានចាប់ខ្លួនអ្នកនេសាទតូចតាច ប៉ុន្តែមិនមែនប្រតិបត្តិកររកប៉ាល់នេសាទធំៗនោះទេ
- នៅពេលកប៉ាល់នេសាទធ្វើនេសាទខុសច្បាប់ អ្នកនេសាទតូចតាចបានរឹបអូសឧបករណ៍នេសាទរបស់ពួកគេ
- កម្មកររកប៉ាល់នេសាទ បានឆ្លើយតបដោយហឹង្សា ដោយបានវាយប្រហារទៅលើអ្នកនេសាទតូចតាច និងបំផ្លាញឧបករណ៍នេសាទរបស់ពួកគេ។
- ពាក្យចចាមអារ៉ាម (ឧទាៈ ស្តីអំពីអ្នកនេសាទស្រែអំបិល បានចាប់ជម្រិតអ្នកនេសាទស្ទឹងហាវ) នាំឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ។
- អង្គការមិនមែនរដ្ឋាភិបាល គាំទ្រសហគមន៍នេសាទនៅស្ទឹងហាវ ធ្វើការផ្នែកសិទ្ធិមនុស្ស រីឯអង្គការ AFSC ធ្វើការផ្នែកការចិញ្ចឹមជីវិតប្រកបដោយចេរភាព ពួកគេមានការយល់ឃើញខុសគ្នា។ ពួកគេបានឮរឿងរ៉ាវអំពីអ្នកនេសាទស្រែអំបិលពីអ្នកនេសាទស្ទឹងហាវ ខុសពីអ្វីដែលបុគ្គលិករបស់ AFSC បានឮ។ ដូច្នេះអង្គការមិនមនរដ្ឋាភិបាលរកឃើញថា វាមានការលំបាកក្នុងការធ្វើការរួមគ្នា ដោយសារការយល់ឃើញរបស់ពួកគេផ្សេងគ្នា។
- ទោះបីជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាល មានទំនាក់ទំនងយ៉ាងល្អ និងមានការគោរពយ៉ាងខ្លាំងពីសំណាក់សហគមន៍ ហើយពួកគេមានបំណងបង្កើនទំនាក់ទំនងរវាងសហគមន៍នេសាទទាំងពីរ (ស្ទឹងហាវ និងស្រែអំបិល)
- អ្នកចំណូលថ្មីមិនសូវយកចិត្តទុកដាក់ថែរក្សាធនធានក្នុងស្រុក ដូចអ្នករស់នៅយូរអង្វែងទេ
- ក្រុមអ្នកនេសាទដែលជាគូប្រជែង (ស្ទឹងហាវ) បានកំណត់សហគមន៍ដោយខ្លួនឯង ហើយពួកគេមានទំនាក់ទំនងតិចតួចបំផុតរវាងក្រុម និងក្រុម។
- ផ្ទះសម្បែងរបស់សហគមន៍នេសាទ គឺជានិមិត្តរូបនៃអំណាចរបស់ក្រុមសហគមន៍នេសាទ និងគោលដៅសម្រាប់ការវាយប្រហារ
- ទោះបីជាមានទំនាស់ក៏ដោយ អ្នកនេសាទទាំងអស់នៅជុំវិញឆកកំពង់សោម មានចំណាប់អារម្មណ៍រួមគ្នាលើនិរន្តរភាពនៃការនេសាទ "ប្រសិនបើត្រីបាត់បង់អស់ ប្រជានេសាទទាំងអស់នឹងរងគ្រោះ"
- រដ្ឋាភិបាលខេត្តកោះកុង និងព្រះសីហនុ មានឆន្ទៈប្រមូលអ្នកពាក់ព័ន្ធមកពិភាក្សារួមគ្នា